ទស្សនាវដ្ដី
សម្លេងខ្មែរនៅបរទេស

# ជុំវិញការលាលែងរបស់ សម្ដេចសីហនុ

(ដកស្រង់ចេញពីទស្សនាវដ្ដី<ការពិត>)
លេខ២១ ខែកញ្ញា ឆ្នាំ២០០១

### ទស្សនៈខ្មែរក្រហមចំពោះមូលហេតុនិងលទ្ធផលនៃការលាលែងរបស់សម្ដេចសីហនុ

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យបានរៀបចំប្រជុំគណៈអចិន្ត្រៃយ៍រណសិរ្ស ដោយមានការចូលរួមពីសំណាក់សមមិត្តលេខា (ប៉ុល-ពត), សមមិត្តអនុលេខា (នួន-ជា), សមមិត្តវន (វន-វ៉េត), សមមិត្តខៀវ (សុន-សេន), សមមិត្តហែម (ខៀវ-សំផន), សមមិត្តឡឿន, សមមិត្តទុំ និងសមមិត្តទូច ។ កិច្ចប្រជុំផ្ដោតសំខាន់ទៅលើរបៀបវារៈតែមួយគត់គឺ «សីហនុលាឈប់ពីតំណែង» ។

នៅក្នុងកំណត់ហេតុនៃអង្គប្រជុំ គណៈអចិន្ត្រៃយ៍រណសិរ្សចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ បញ្ជាក់ថា សមមិត្តហែម (ខៀវ-សំផន) បានរាយការណ៍ជូនអចិន្ត្រៃយ៍ អំពីការលាឈប់របស់សម្ដេចសីហនុ ។ សម្ដេចសីហនុបានផ្ញើសំបុត្រជាភាសាបារាំងជូនអង្គការពីរច្បាប់ ។ ច្បាប់ស្នើសុំលាឈប់ ហើយបញ្ជាក់ពីមូលហេតុសំខាន់ៗ ដែលនាំឲ្យសម្ដេចលាឈប់ ពិសេសសម្ដេចចង់សង្កត់លើបញ្ហារោគផ្សេងៗរបស់សម្ដេច ដែលពុំអនុញ្ញាតឲ្យសម្ដេចបន្តទៅទៀតបាន ។ រីឯមួយច្បាប់ទៀតជាសេចក្ដីរាយការណ៍ចំពោះប្រជាជនកម្ពុជាប្រជាធិបតេយ្យថា សម្ដេចលាឈប់មុនថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ។

កំណត់ហេតុបានកត់សម្គាល់ការត្អូញត្អែររបស់សម្ដេចសីហនុថា «ពេលជួបទូតម៉ូរីតានីនិងទូតសេណេហ្គាល់ សីហនុក៏បានប្រាប់ថា គាត់លាឈប់ដាច់ខាតដែរ ។ ដល់ជួបគណៈប្រតិភូសេដ្ឋកិច្ចពាណិជ្ជកម្មចិនគាត់ត្អូញអំពីជម្ងឺគាត់» ។ សម្ដេចសីហនផ្ទាល់ព្រះអង្គ ក៏បានថ្លែងទៅកាន់អ្នកដែលស្រឡាញ់គោរពព្រះអង្គនៅទីក្រុងបែលក្រាដ មុនពេលទ្រង់សំរេចព្រះទ័យយាងចូលមកកម្ពុជាវិញថា «រដ្ឋាភិបាលប្រទេសខ្ញុំបានសុំឲ្យខ្ញុំបំពេញបេសកកម្មមួយនៅអង្គការសហប្រជាជាតិ និងនៅតាមបណ្ដាប្រទេសជាង១០ទៀត ។ បេសកកម្មនេះត្រូវបញ្ចប់នៅថ្ងៃនេះ ។ ខ្ញុំនឹងមិនបំពេញបេសកកម្មផ្សេងទៀត ដើម្បីបំរើផលប្រយោជន៍របបថ្មីឡើយ ។ ខ្ញុំមានបំណងសុំលាពីមុខតំណែង ។ ប៉ុន្តែខ្ញុំបានចាត់ទុកខ្លួនឯងថាជាទាហានម្នាក់ដែលកំពុងចង់ធ្វើខ្លួន ឲ្យគេបញ្ចេញពីកំណែនទ័ព ដូច្នេះខ្ញុំត្រូវតែត្រឡប់ចូល <បន្ទាយ> ដើម្បីដូរសំលៀកបំពាក់ស៊ីវិលចេញមកវិញ» ។

តាមមតិរបស់អង្គការ មូលហេតុដែលនាំសម្ដេចសីហនុលាឈប់មានពីរយ៉ាងគឺ ÷ ១) មូលហេតិវែងឆ្ងាយ និង២)មូលហេតុចំពោះមុខ ។ អង្គការឲ្យហេតុផលថា ចំពោះមូលហេតុវែងឆ្ងាយ គឺទំនាស់វណ្ណៈជាមូលដ្ឋាន រវាងបដិវត្តន៍និងសម្ដេចព្រមទាំងគ្រួសារ ។ «គាត់នៅជាមួយយើងមិនបាន ។ កន្លងមកគាត់រស់នៅជាយុទ្ធវិធីទេ ។ ដោយយើងដំណើរការជាយុទ្ធវិធីទៅ គាត់ចេះតែនៅបណ្ដើរៗ ។ សីហនុមិនមែនលាឈប់តែម្ដងទេ ។ គាត់លាឈប់តាំងពីឆ្នាំ១៩៧១មក» ។

«មតិអង្គការ»បន្តទៀតថា មូលហេតុចំពោះមុខគឺទំនាស់ជាយុទ្ធវិធីវាបន្ថែមពីលើទំនាស់ជាមូលដ្ឋាន ។ ហេតុផលលាលែងរបស់សម្ដេចសីហនុ ត្រូវបានអង្គការលើកជាឧទាហរណ៍បញ្ជាក់ច្បាស់ថា «ដូចជាយើងត្រូវឲ្យទូតចេញទៅក្រៅដោយពុំសួរគាត់ ។ គឺជារឿងតូចតាចទេ តែគាត់ស្មានថា ប្រហែលយើងលែងត្រូវការគាត់ហើយ ។ ដូច្នេះ ទំនាស់ក៏ចង់បានតំណែងតទៅទៀតដែរ» ។

ខ្មែរក្រហមហាក់ទាញយកផលប្រយោជន៍ពីសម្ដេចសីហនុសំរាប់បញ្ហាក្រៅប្រទេស ។ ប៉ុន្តែសំរាប់កិច្ចការក្នុងប្រទេស ពិសេសការដឹកនាំខ្មែរក្រហមមិនត្រូវការទ្រង់ឡើយ ។ ដូចដែលសៀវភៅកំណត់ហេតុរបស់ខ្មែរក្រហមបានគូសបញ្ជាក់ថា «តស៊ូប្រជាជាតិ តស៊ូប្រជាធិបតេយ្យដើម្បីឈានចូលសង្គមនិយម ចំពោះសម្ដេចសីហនុគឺយើងឲ្យនៅដដែល តែត្រូវបក្សយើងដឹកនាំ និងដើម្បីឲ្យគាត់ទប់ទល់នូវសត្យានុម័ត ដែលបុកពីខាងក្រៅ ហើយដាច់ខាតមិនឲ្យបុគ្គលនេះក្ដាប់រដ្ឋអំណាចទេ» ។ ដូច្នេះនៅក្រោមក្រសែភ្នែករបស់ខ្មែរក្រហម សម្ដេចសីហនុមិនមែនជាធាតុផ្សំដ៏សំខាន់របស់ក្បាលម៉ាស៊ីនខ្លួនទេ ។ «ក្រោយរដ្ឋប្រហារ ចលនាបដិវត្តន៍យើងវិវត្តដោយលោតផ្លោះ ដោយកត្តាអត្តនោម័តរបស់យើងក៏គ្រប់គ្រាន់ កត្តាសីហនុបន្ថែមទៀត ហើយសកលលោកជួយឧបត្ថម្ភទៀត» ។ សម្ដេចសីហនុបានសារភាពថា ក្នុងរយៈពេលដែលព្រះអង្គកាន់មុខតំណែងក្រុមប្រឹក្សារដ្ឋមន្ត្រី ឬប្រមុខរដ្ឋខ្មែរក្រហម ព្រះអង្គបានធ្វើអធិបតីភាពពេញលេញក្នុងការប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រីពីរដងប៉ុណ្ណោះ ។ ការប្រជុំទី១បានព្រព្រឹត្តទៅនៅខែកញ្ញាឆ្នាំ១៩៧៥ ដែលកាលណោះខៀវ-សំផន, សុន-សេន, ហ៊ូ-នឹម, កុយ-ធួន, តូច-ភឿន បានធ្វើសេចក្ដីរាយការណ៍» ថ្វាយព្រះអង្គម្នាក់ម្ដងៗ ស្ដីពីលទ្ធផលនៃស្នាដៃផ្សេងៗ ដែលទទួលបានតាមក្រសួងរៀងៗខ្លួន ក្នុងចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ដំណើរយាងនិវត្តន៍របស់ព្រះអង្គមកកាន់ប្រទេសកម្ពុជាវិញនៅខែកញ្ញា ក្នុងឆ្នាំដដែល ។

មតិអង្គការរៀបរាប់ពីជីវិត បរិយាកាសជុំវិញ និងជម្រើសរបស់សម្ដេចសីហនុថា «សម្ដេចអត់ការធ្វើ អផ្សុក ហើយបរិយាកាសនៅជុំវិញ ពិសេសប្រពន្ធឃុំជាប់ ជំរុញឲ្យគាត់ទ្រាំមិនបាន ។ បើនៅតទៅទៀតក៏មិនយូរ យ៉ាងច្រើនមួយឆ្នាំឬពីរឆ្នាំ ។ បើគង់តែទៅជាដដែល ទៅមុនឲ្យហើយទៅល្អជាង» ។

សម្ដេចសីហនុក៏មានព្រះបន្ទូលត្អូញត្អែរស្រដៀងគ្នានេះដែរថា «ខ្ញុំគ្មានកិច្ចការណាមួយ ដែលត្រូវធ្វើសំរាប់ប្រទេសខ្ញុំ ឬអតីតប្រជារាស្ត្រខ្ញុំឡើយ ។ ដោយត្រូវគេដាក់ឲ្យស្ថិតនៅក្នុងសភាពជាមនុស្សគ្មានការងារធ្វើដូច ភូរីស្សារ៉ា ដែលអួតថាជារដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ខ្មោចនោះ ខ្ញុំបានសាកល្បងរំសាយទុក្ខកង្វល់ ដោយអានអត្ថបទផ្សេងៗដែលរៀបរាប់ពីម្ហូបឆ្ងាញ់ៗនៅប្រទេសបារាំង ខ្ញុំនឹកស្រមៃដល់ប្រទេសបារាំង ដើម្បីព្យាយាមបំភ្លេចកម្ពុជាដ៏អភ័ព្វរបស់ខ្ញុំ» ។

កិច្ចប្រជុំគណៈអចិន្ត្រៃយ៍សម្ដែងនូវមោទនភាពថា ប្រជាជនកម្ពុជាទាំងមូល កម្មាភិបាល និងកងទ័ពទាំងអស់ បានដកដង្ហើមធំចុងក្រោយរបស់ខ្លួនផុតហើយ រីឯដំណោះស្រាយការចាត់តាំងក្នុងអង្គការរដ្ឋយើងបានស្រួល ហើយគ្មានពាក់ព័ន្ធអ្វីទៀតទេ ។ ចំពោះកិច្ចការបរទេសដែលខ្មែរក្រហមយល់ថា សម្ដេចសីហនុជាកត្តាចំបងនោះ ក៏ត្រូវអង្គការមានសុទិដ្ឋិនិយមថា នឹងគ្មានបញ្ហាដែរ ក្រោយពេលសម្ដេចសីហនុសុំលាលែង ។ «ការងារបរទេសយើងនឹងល្អជាងមុន ព្រោះយើងធ្វើខ្លួនយើង

យើងយកជំហរខ្លួនយើង ព្រោះអត់សីហនុយើងជ្រះស្រឡះ» ។

ទាក់ទងនឹងបច្ច័យអវិជ្ជមាននៃការលាលែងរបស់សម្តេចសីហនុ មតិអង្គការបានលើកឡើងថា «ម៉្យាងទៀតវៀតណាមវាយយើងថាយើងឆ្វេង ។ សីហនុជួយយើង ម៉េចចោលសីហនុ ។ វាប្រាប់បដិវត្តន៍ផ្សេងៗលើកល្បពីខ្លួនវា បន្ទុះបង្អាប់យើង» ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី «បញ្ហានេះជាបញ្ហាបណ្តោះអាសន្នទេ ។ ឲ្យតែយើងនៅជិតស្និទ្ធនឹងគេទៅ អត់ចោទអីទេ» ។

ទោះជាក្នុងដំណាក់កាលនេះខ្មែរក្រហមលែងត្រូវការសម្តេចសីហនុក៏ដោយចុះ ក៏ខ្មែរក្រហមទទួលស្គាល់ពីស្នាព្រះហស្ថ សមត្ថភាព និងគុណូបការៈរបស់សម្តេចចំពោះជាតិដែរ ។ «គោលជំហរយើងទាំងអស់គ្នា ទាំងរដ្ឋាភិបាល គឺនៅតែថាគាត់មានសគុណលើប្រទេស ពិសេសនៅលើឆាកអន្តរជាតិ ។ គាត់មានសគុណលើជាតិ ដែលមហាសន្និបាតបានសំរេចហើយ។ យើងគោរពសម្ទហភាពណាស់ បើថាម៉េចគឺអីចឹងហើយតែសុំឲ្យគាត់នៅជាមួយប្រជាជនទៀត ។ ប្រជាជនតម្កល់ទុកសគុណគាត់ទៅទៀត យើងមានអំណរសាទរណាស់ ហើយខំឲ្យអស់លទ្ធភាព អនុវត្តនូវសេចក្តីសំរេចចិត្តរបស់មហាសន្និបាតជាតិពិសេសរបស់យើង» ។

នៅក្នុងទិសដៅទីពីរដែលជាប្រការទប់ទល់នឹងការមិនព្រមលាលែងរបស់សម្តេចនោះ អង្គការបានលើកឡើងថា «យើងនឹងប្រជុំគណៈរដ្ឋមន្ត្រីដើម្បីសំរេច» ។ បើតាមសេចក្តីរាយការណ៍របស់សមមិត្តហែម សម្តេចសីហនុ ហាក់ដូចជាមិនក្រាញនឿលដូចដែលគណៈប្រជុំអចិន្ត្រៃយ៍បានគិតនោះទេ ។ នៅក្នុង«មតិរបស់អង្គការក្នុងអង្គប្រជុំយប់ថ្ងៃទី១៣» សមមិត្តហែមបញ្ជាក់ច្បាស់ថា «គាត់សំរេចសុំលាលែងពីតំណែងដាច់ខាត» ។ សមមិត្តហែមបន្ថែមទៀតថា សម្តេចសីហនុទទូចហើយទទូចទៀតថា «សូមអង្គការអាណិតឲ្យខ្ញុំផង ។ ឲ្យខ្ញុំសំពះ លូនក៏បានដែរ ឲ្យតែបានឈប់» ។

សមមិត្តលេខាចាត់ទុកការលាលែងនេះជាបញ្ហាធំ ៖ «ទុកឲ្យអង្គការមជ្ឈិមយើងជាអ្នកអារកាត់ចុះ» ។ ទន្ទឹងនឹងពេលគ្នានេះដែរ សមមិត្តលេខាបានព្រាងជាគោលគំនិតដែលអង្គការអចិន្ត្រៃយ៍ទាំងមូលយល់ស្របដែរ ។ គំនិតសំខាន់ៗមានដូចជា មិនឲ្យសម្តេចចេញទៅក្រៅប្រទេស ប្រជុំគណៈរដ្ឋមន្ត្រីដើម្បីសំរេច រួចហើយទៅជួបសម្តេចទៀត ដោយមានប៉ែន-នុតចូលរួមដែរ និងវាយខ្សែរលួស «ឲ្យកូនគាត់មកភ្លាមដោយបញ្ជាក់ថា ឲ្យមករួមចូលឆ្នាំនិងបុណ្យឯករាជ្យ ។ យើងចង់ដោះស្រាយបញ្ហានេះឲ្យបានស្អាត ។ យើងត្រូវដោះស្រាយយ៉ាងនេះ ទើបចំណេញបដិវត្តន៍» ។

«មតិអង្គការ»បន្ថែមថា ទោះជាសម្តេចសីហនុមានទំនាស់ជាមួយនឹង«យើង»ក្តី ប៉ុន្តែសម្តេចបានចូលរួមជាមួយនឹង«យើង»ដែរ ។ ដោយហេតុនេះហើយបានជាបក្សសំរេចឲ្យសម្តេចធ្វើជាគណៈប្រធានរដ្ឋទៀត ។ មតិអង្គការបាននិយាយចាក់បណ្តោយថា «តែគាត់មិនព្រម ។ ដូច្នោះគាត់នៅបានឬមិនបានជារឿងរបស់គាត់» ។

ប៉ុន្តែកំណត់ហេតុប្រជុំអចិន្ត្រៃយ៍អះអាងដោយគ្មានមូលដ្ឋានច្បាស់លាស់ថា «យើងចាត់ទុកគាត់ជាឥស្សរជនមួយរូប ។ យើងមិនកាប់សម្លាប់គាត់ទេ ។ តែចំពោះប្រជាជាតិនិងប្រជាជន គាត់ក៏មានទោសធ្ងន់ក្នុងឋានៈជាអ្នកកាប់សម្លាប់ប្រជាជន ហើយទាញសេចក្តីសន្និដ្ឋានថា «ការសំរេចរបស់យើងសមហេតុសមផលគ្រប់យ៉ាង ។ យើងនៅតែថែរក្សាគាត់។ តែបើគាត់នៅតែរើបំរះ យើងត្រូវបញ្ចប់» ។

«មតិអង្គការ»ក្នុងអង្គប្រជុំយប់ថ្ងៃទី១៣ (ខែមីនា) បានប្រើពាក្យធ្ងន់ៗថា ទិសវិវត្តរបស់បដិវត្តន៍ គឺត្រូវបញ្ចប់សក្តិភូមិយ៉ាងដូច្នេះឯង ។ ក្រឡាអុកវាចេញមកដល់ត្រឹមហ្នឹងហើយ ។ របបសក្តិភូមិទាំងមូលត្រូវបដិវត្តន៍កំទេចនិងគាស់រំលើងជាស្ថាពរ ។ អង្គការនៅបានបន្ថយពាក្យថា «ស្តេចដែលមានមកពីរពាន់ឆ្នាំហើយ ទីបំផុតត្រូវស្អាត» ហើយថា «យើងគ្មានផ្លូវអីចេញក្រៅពីនេះទេ» ។ ទាក់ទងនឹងប្រតិកម្មដែលអាចកើតមានចំពោះវិធានការរបស់អង្គការ មានការនិយាយបង្ការទុកជាមុនថា «ប្រតិកម្មច្បាស់ជាមានខ្លះ តែយើងត្រូវតែដើរតាមផ្លូវបដិវត្តន៍ចំពេញ» ហើយថាចាប់ពីថ្ងៃនេះទៅលែងឲ្យសម្តេច(សីហនុ) ជួបទូតបរទេស ហើយពន្យល់គេដោយលេសសមរម្យ ។៚

---

# ឯកសារ

# សេចក្តីថ្លែងការណ៍ របស់សម្តេចនរោត្តម_សីហនុ ថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦

ដកស្រង់ចេញពីសៀវភៅ

**<The CAMBODIA FILE> by Jack Anderson**

(បកប្រែក្រៅផ្លូវការ)

នេះគឺជាមោទនភាពនិងជាកិត្តិយសដ៏មហាអស្ចារ្យសំរាប់ខ្ញុំ ដែលចាប់ពីខែមិនា១៩៧០មកទល់ថ្ងៃនេះ បាននាំប្រជាជនកម្ពុជាជាទីស្នេហាដ៏ខ្ពង់ខ្ពស់បំផុតរបស់ខ្ញុំ ក្នុងដំណើរប្រវត្តិសាស្ត្រដ៏អស្ចារ្យ និងប្រកបដោយកិត្យានុភាព ដែលក្នុងពេលឥឡូវនេះ ដឹកមុខកម្ពុជាឆ្ពោះទៅរកសករាជថ្មីមួយ ដែលប្រជាជនពុំមែនត្រឹមតែជាម្ចាស់លើភ័ព្វវាសនារបស់ខ្លួនឯងប៉ុណ្ណោះទេ តែជាម្ចាស់លើជាតិ ព្រមទាំងបេតិភូមិផងដែរ ។ គឺជាយុគសម័យថ្មីមួយដែលគ្មានមន្ទិលសង្ស័យអ្វីទាំងអស់ ប្រកបដោយពន្លឺរស្មីយ៉ាងត្រចះត្រចង់ក្រៃលែង ក្នុងអំឡុងពីរពាន់ឆ្នាំនៃសាវតាជាតិយើង ។

ពេលរដ្ឋប្រហាររបស់លន់-នល់ ជាមួយពួកបនរបស់គាត់ ធ្វើឡើងនៅភ្នំពេញកាលពីថ្ងៃទី១៨ មិនា ១៩៧០, ខ្ញុំបានស្បថខ្លួនឯង និងចំពោះប្រជាជនកម្ពុជាថា បន្ទាប់ពីខ្ញុំបានដឹកនាំប្រជារាស្ត្ររបស់ខ្ញុំ សំរេចជោគជ័យលើពួកមូលធននិយមអាមេរិកាំង ជាមួយបនពួកក្បត់រួចហើយ និងបន្ទាប់ពីបើកទ្វារយុគបដិវត្តន៍ថ្មី... ខ្ញុំនឹងចូលនិវត្តន៍ទាំងស្រុង នឹងចាកចេញពីឆាកនយោបាយរហូតតទៅ រួចហើយមុខនាទីរបស់ខ្ញុំក៏ដល់ទីបញ្ចប់ផងដែរ ។

ថ្ងៃនេះ, សុបិន្តរបស់ខ្ញុំ ដែលចង់ឃើញកម្ពុជាងើបមកវិញ និងពង្រឹងរហូតតទៅ នូវឯករាជភាព, អធិបតេយ្យភាព, បូរណភាពទឹកដី និងអព្យាក្រឹត្យភាព ព្រមទាំងបានទទួលនូវប្រព័ន្ធមួយផ្តល់ដល់ប្រជាជន និងជាតិ នូវអធិបតេយ្យភាពយ៉ាងពិតប្រាកដ ព្រមទាំងយុត្តិធម៌ឥតខ្ចោះក្នុងសង្គម ហើយនិងអាយុជីវិតជាតិដែលស្អាតស្អំជាទីបំផុត (សៅហ្មងជ្រះពីកំអែលអំពើពុករលួយ និងរោគសង្គមផ្សេងឯទៀត) បានត្រូវបំពេញលើសហួសពីការនឹកស្រមើស្រមៃរបស់ខ្ញុំទៅទៀត ។ សូមអរគុណអ្នកតស៊ូទាំងប្រុសទាំងស្រីរបស់យើង ប្រជាកសិករ កម្មករ និងពលករដទៃទៀត ដែលស្ថិតនៅក្រោមការដឹកនាំនៃអង្គការបដិវត្តន៍ដ៏ភ្លឺស្វាងរបស់យើង ។

ដូច្នេះ, បំណងដ៏ជ្រាលជ្រៅទាំងអស់របស់ខ្ញុំ ក៏បានក្លាយមកជាការពិត ។ មិនតែប៉ុណ្ណឹងសោត កម្ពុជារបស់យើងក៏បានសំរេចជោគជ័យដូចប្រាថ្នា ។ សូមអរគុណដល់វីរៈបុរសនិងវីរៈនាទីបដិវត្តន៍ បានបំពេញនូវស្នាដៃដ៏មហាឧត្តុងឧត្តម ដែលនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សលោក គឺ

ជាលើកដំបូងបង្អស់ហើយ បានកាច់បំបាក់អំពើក្រអឺតក្រទម និងមិនព្រមចុះញ៉មនៃមូលធននិយមអាមេរិកាំង ដែលជាពួកមូលធននិយមដ៏ខ្លាំងក្លា, ឃោរឃៅ និងដ៏ស្វិតស្វាញជាងគេ ដែលពិភពលោកពុំដែលបានជួបប្រទះ ។

ចំណែកខ្លួនខ្ញុំផ្ទាល់វិញ បន្តិចក្រោយពេលរំដោះបេតុភូមិ, ប្រជាជនយើង, អង្គការបដិវត្តន៍យើង និងកងទ័ពបដិវត្តន៍ បានផ្តល់កិត្តិយសយ-សយ៉ាងឱឡារិកដល់រូបខ្ញុំ ក្នុងនាមជាអ្នកស្នេហាជាតិ និងជាសមាជិកនៃក្រុមតស៊ូ ព្រមទាំងក្នុងពេលជាមួយគ្នា បានប្រគល់មកឲ្យខ្ញុំសារជាថ្មី នូវមុខនាទីជាប្រមុខរដ្ឋកម្ពុជា ។ ពួកគេបានយាងខ្ញុំឲ្យវិលត្រឡប់ជាផ្លូវការចូលមកកាន់កម្ពុជា ដូចដែលពួកគេធ្លាប់បានស្វាគមន៍ខ្ញុំ កាលពីខែមិនាឆ្នាំ១៩៧៣ នាពេលសង្គ្រាមដូច្នោះដែរ ។ ហើយក៏ដូចគ្នា គេបានស្វាគមន៍ខ្ញុំយ៉ាងកក់ក្តៅក្រៃលែង ពោរពេញទៅដោយការស្រឡាញ់ គោរពរាប់អាន់ និងដោយមោទនភាពដ៏អស្ចារ្យ ។ ពួកគេបានបង្ហាញឲ្យខ្ញុំឃើញ នូវជោគជ័យរាប់មិនអស់និងដ៏គួរឲ្យរំភើបចិត្ត ក្នុងចំណោមនោះមាន ប្រព័ន្ធផ្លូវទឹកថ្មីៗ ដែលនឹងធានាធ្វើឲ្យស្រុកទេសរបស់យើង ក្លាយទៅជាស្រុកជឿនលឿនជាងគេទាំងអស់ និងជាស្រុករីកចំរើនយ៉ាងខ្ពស់ត្រដែតត្រដឹមនៅក្នុងវិស័យកសិកម្មជាតិ ។

ការសប្បាយចិត្តរបស់ខ្ញុំ... ធំជាងអ្វីដែលខ្ញុំពុំអាចនឹកស្រមៃទៅដល់

ជាមួយមនោសញ្ចេតនានេះ និងជាមួយការតាំងចិត្តរបស់ប្រជាជននិងអង្គការបដិវត្តន៍របស់យើង ដែលបានឃោគយល់ខ្ញុំជាសមាជិកម្នាក់ ខ្ញុំសុំអនុញ្ញាតទាំងអស់គ្នាចូលនិវត្តន៍ក្នុងថ្ងៃនេះ។ ខ្ញុំសូមធានាថា នៅគ្រប់ទីកន្លែងនិងគ្រប់កាលៈទេសៈណាទាំងអស់ ខ្លួនខ្ញុំនឹងនៅតែជាអ្នកគាំទ្រយ៉ាងក្លៀវក្លានៃប្រជាជនកម្ពុជា, បដិវត្តន៍, សភាតំណាងប្រជាជន, រដ្ឋាភិបាល, គណៈកម្មាភិបាលដឹកនាំរដ្ឋ, អង្គការបដិវត្តន៍ ព្រមទាំងកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យជានិច្ចរៀងទៅ ។

ជយោវិរៈបុរសដ៏អង់អាចក្លាហាននៃប្រជាជនកម្ពុជា !

ជយោកម្ពុជាប្រជាធិបតេយ្យ !

ជយោរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ !

សម្លេងខ្មែរនៅបរទេស

# ខ្មែររំដោះ ឬខ្មែរក្រហម?

ដោយ លី-ឡៀប ★ ថ្ងៃទី១២ មេសា ២០០៤

ស្ដេចសីហនុតែងហៅក្រុមតស៊ូរបស់ព្រះអង្គ ដែលបានបង្កើតឡើងកាលពីឆ្នាំ១៩៧០ ថាជា «កងទ័ពខ្មែររំដោះ» ។ ក៏ប៉ុន្តែតាមការពិតវិញនោះ កងទ័ពនេះគឺជាកងទ័ពដែលយួនហាណូយបានបំពាក់អាវុធបំពាក់ស្មារតីចាប់តាំងពីឆ្នាំ១៩៥០មកម្ល៉េះ ។ ស្ដេចសីហនុនៅក្រោយពេលត្រូវពួកមេដឹកនាំខាងប្លុកកុម្មុយនិស្ត (ចិននិងយួនជាពិសេស) ពន្យល់ បញ្ចុះបញ្ចូល និងបង្ហាញឲ្យឃើញអំពីជ័យជំនះរបស់ខ្លួននៅក្នុងសង្គ្រាមវៀតណាម ព្រះអង្គក៏ទោរទន់និងបែកប្រាជ្ញានឹកព្រួចចង់ធ្វើជា <មហាវិរៈបុរសរំដោះជាតិ> ដូចហូ-ជីមិញដែរ ។ ការដែលអាចធ្វើដូច្នេះទៅបាន ស្ដេចសីហនុតោងរៀបចំឆាកនយោបាយមួយ ដើម្បីព្រះអង្គមានឱកាសហក់ទៅចូលរួមដៃជាមួយខាងពួកកុម្មុយនិស្ត ដែលព្រះអង្គធ្លាប់បានចាត់ទុកថា ជា<សត្រូវស្លាប់រស់>របស់ខ្លួនកាលពីពេលមុននេះបន្តិច ។

ព្រឹត្តិការណ៍១៨ មិនា ១៩៧០ គឺត្រូវចាត់ទុកថា ជាព្រឹត្តិការណ៍យ៉ាងប្រណិតរបស់ស្ដេចសីហនុ រុញស្រុកខ្មែរឲ្យងាកទៅខាងអាមេរិកាំងសំរាប់ធ្វើជា<លេស>ដើម្បីឲ្យព្រះអង្គអាចលោតចូលទៅខាងកុម្មុយនិស្តបង្ក<ទ័ពទីង>រំដោះស្រុកខ្មែរ ដែលព្រះអង្គបានច្រានទៅនោះមកវិញ ។

ដល់ដូច្នេះទៅ, ស្រុកខ្មែរនៅក្នុងសន្តិភាពយ៉ាងសុខក្សេមក្សាន្តសោះក៏បានត្រូវស្ដេចខ្លួនឯងយក<ភ្លើង>មកដុត ដើម្បីគ្រាន់តែបំរើមហិច្ឆិតារអើរវាយផ្ទាល់ខ្លួនប៉ុណ្ណោះ ។ ស្ដេច<ណោរុង>ខ្មែរនេះ មិនគ្រាន់តែដុតស្រុកខ្មែរសំរាប់ដេញចាប៉ីស្ដាប់ឲ្យពិរោះត្រចៀកនោះទេ ជាលទ្ធផលចុងក្រោយគឺបានជ្រុលដៃរហូតដល់ធ្វើឲ្យស្រុកខ្លួនឯង ប្រែក្លាយទៅជា<ផ្នូរខ្មោច>មួយយ៉ាងអាណោចអធមក្រៃលែងនៃសតវត្សទី២០ ។

ដើម្បីយល់ដឹងអំពី<កងទ័ពរំដោះ>របស់ស្ដេចសីហនុ ជាកងទ័ពប្រភេទណា យើងសូមជនរួមជាតិក្រឡេកមើលសមាសភាពនៃ<រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា> (FUNK), <រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា> (GRUNK) និង<កងទ័ពប្រជាជនរដោះជាតិកម្ពុជា> (FAPLNK) ដែលស្ដេចសីហនុបានបង្កបង្កើតឡើង កាលពីថ្ងៃទី២៣ មិនា ឆ្នាំ១៩៧០ នៅទីក្រុងប៉េកាំង ៖

១- <u>រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា (FUNK)</u> ៖

★ ប្រមុខរដ្ឋនិងជាប្រធាន ៖ សម្ដេចនរោត្តម-សីហនុ

<u>ការិយាល័យគណៈកម្មាធិការមជ្ឈិម</u> ៖

★ ប្រធាន ៖ ប៉ែន-នុត

★ អគ្គលេខាធិការ ៖ ជួន-ប្រសិទ្ធ

★ សមាជិក ៖ ចាន់-យូរ៉ាន់, ចៅ-សេង, ជា-សាន, ឧត្តមសេនិយដួង-សំអុល, ហ៊ូ-យន់, ហ៊ូ-នឹម, ហួត-សម្បត្តិ, ខៀវ-សំផន, សារិន-ឆាក, ជួន-មុម ។

<u>គណៈកម្មាធិការមជ្ឈិម</u> ៖

អាង-គីមឃន, ចាន់-យូរ៉ាន់, ចៅ-សេង, ជា-សាន, ថែម-ស្ហួន, ជូ-ជេត, ឧត្តមសេនិយដួង-សំអុល, ហាក់-ស៊ាបឡាយនី, ហាន-ម៉ាត, ហៃ-គីមស៊ាង, ហ៊ូ-យន់, ហេង-ពេជ្រ, ហ៊ូ-នឹម, ហួត-សម្បត្តិ, អ្នកស្រីអៀងធីរិទ្ធ, អ៊ិន-សូកាន, គាត-ឆុន, កែវ-មាស, ខៀវ-សំផន, គង់-សូឌិប, កុយ-ធួន, គ្រិន-លៀង, លី-អ៊ន, ម្ចាស់ក្សត្រីម៉ូនិក-សីហនុ, ង៉ៅ-ហ៊ូ, ង៉ៅតាំងទីតា, អ៊ុក-សាគុន, អ៊ុង-មៀន, សម្ដេចប៉ែន-នុត, ប៉ុក-ដើសកុមារ, រស់-ថុល, សារិន-ឆាក, សេង-ចុងកាល, ស៊ាង-អាន, សុខ-ធួក, ស្អួងសាគឿន, ជួន-មុម, ជួន-ប្រាសិទ្ធ, ទីវ-អុល, តូច-ខាំឌឿន, អ៊ុង-បញ្ញារិទ្ធ វ៉ាន់-ពីនី ។

២- <u>រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (GRUNK)</u> ៖

★ នាយករដ្ឋមន្ត្រី ៖ សម្ដេចប៉ែន-នុត

★ ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការពារជាតិ ៖ ខៀវ-សំផន

★ រដ្ឋមន្ត្រីអមប្រធាននៃក្រុមប្រឹក្សាគណរដ្ឋមន្ត្រី ៖ គាត-ឆុន

★ រដ្ឋមន្ត្រីក្រសួងការបរទេស ៖ សារិន-ឆាក

★ រដ្ឋមន្ត្រីក្រសួងពត៌មាននិងឃោសនា ៖ ហ៊ូ-នឹម

★ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, កែទំរង់ជនបទ និងសហករណ៍ ៖ ហ៊ូ-យន់

★ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងហិរញ្ញវត្ថុ ៖ ជួន-មុម

★ រដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ៖ ចៅ-សេង

★ រដ្ឋមន្ត្រីទទួលបន្ទុកសំរបសំរួលការតស៊ូរំដោះជាតិ ៖ ជួន-ប្រសិទ្ធ

★ រដ្ឋមន្ត្រីកសួងអប់រំប្រជាជននិងយុវជន ៖ ចាន់-យូរ៉ាន់

★ រដ្ឋមន្ត្រីក្រសួងឧបករណ៍និងអាវុធយុទ្ធភ័ណ្ឌ ៖ ឧ. ដួង-សំអុល

★ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងកែទំរង់តុលាការ ៖ ជា-សាន

★ រដ្ឋមន្ត្រីក្រសួងសាធារណការ, ទូរគមនាគមន៍ និងកសាងឡើងវិញ ៖ ហួត-សម្បត្តិ

★ រដ្ឋមន្ត្រីក្រសួងសុខាភិបាល, សាសនា និងសង្គមកិច្ច ៖ ង៉ៅ-ហ៊ូ

★ រដ្ឋមន្ត្រីគ្មានទទួលបន្ទុកអ្វី ៖ ព្រះអង្គម្ចាស់នរោត្តម-ភូរិស្សរ៉ា

★ អនុរដ្ឋមន្ត្រីក្រសួងការបរទេស ៖ ប៉ុក-ដើសកុមារ

★ អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ ៖ គង់-សូឌិប

★ អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងសន្តិសុខជាតិ ៖ សុខ-ធួក

★ អនុរដ្ឋមន្ត្រីក្រសួងពត៌មាននិងឃោសនា ៖ ទីវ-អុល

★ អនុរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៖ កុយ-ធួន

★ អនុរដ្ឋមន្ត្រីក្រសួងអប់រំប្រជាជន និងយុវជន ៖ អ្នកស្រីអៀង-ធីរិទ្ធ

★ អនុរដ្ឋមន្ត្រីក្រសួងសុខាភិបាល, សាសនា និងសង្គមកិច្ច ៖ ជូ-ជេត

៣- <u>អគ្គបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជា (FAPLNK)</u> ៖

★ ប្រធាន ៖ ខៀវ-សំផន, អគ្គបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជា

★ អនុប្រធាន ៖ សាឡុត-សរ, មេបញ្ជាការដឹកនាំខាងកងទ័ព

★ អនុប្រធាន ៖ នួន-ជា, មេបញ្ជាការដឹកនាំខាងនយោបាយ

★ អនុប្រធាន ៖ សូ-វណ្ណា, មេបញ្ជាការរងដឹកនាំខាងកងទ័ព

★ សមាជិក ៖ ជួន-ឈិត, មេបញ្ជាការដឹកនាំខាងផ្នែកអាវុធយុទ្ធភ័ណ្ឌ

★ សុន-សេន, អគ្គបញ្ជាការនៃគណៈកម្មាអិការរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា ប្រចាំក្រុងភ្នំពេញ

- ប្រធាន ៖ ព្រះអង្គម្ចាស់នរោត្តម-ភូរិស្សរ៉ា
- អនុប្រធាន ៖ ជួន-ជឿន
- អនុប្រធាន ៖ អ្នកស្រីខៀវ-ប៉ុណ្ណារី, តំណាងស្ត្រី
- សមាជិក ៖ តូច-ភឿន, តំណាងអ្នករាជការ, ភោគ-ឆាយ តំណាងយុវជននិងនិស្សិត, ងួន-អេង តំណាងកម្មករ, រស់-ជេតធរ តំណាងអ្នកនិពន្ធនិងអ្នកកាសែត ។

★★★ បើយើងពិនិត្យមើលសមាភាពទាំងអស់ខាងលើនេះ ស្ទើរតែ

ទាំងអស់ ជាពិសេសពួកមេបញ្ជាការ<កងទ័ពប្រជាជនរំដោះជាតិកម្ពុជា> ដែលស្តេចសីហនុហៅយ៉ាងសាមញ្ញថា <កងទ័ពរំដោះ> នោះ គឺសុទ្ធតែក្តោបក្តាប់ដោយពួកមេៗខ្មែរក្រហមទាំងអស់ ។

យើងធ្លាប់បានធ្វើសំនួរជាច្រើនដងទៅស្តេចសីហនុរួចហើយ អំពីឈ្មោះ<មេកងទ័ពរំដោះ> ដែលព្រះអង្គតែងអួតខ្លាយៗមិនឈប់មិនឈរសោះនោះ តែស្តេចសីហនុមិនដែលបានបង្ហាញឲ្យស្គាល់មេទ័ពដ៏ខ្លាំងពូកែ ជា<មនុស្សសីហនុនិងមិនមែនកុម្មុយនិស្តនិយម> សូម្បីតែម្នាក់ក៏គ្មានដែរ ។ សួរថាហេតុអ្វីបានជាគ្មាន ? ចម្លើយគឺមកពី<គ្មាន> ។ ពួកមេទ័ពទាំងអស់នោះជាមេខ្មែរក្រហម ដែលធ្វើការប្រយុទ្ធស្មាទល់ស្មាជាមួយពួកយៀកកុង-យៀកណាមខាងជើង ដោយមានការគាំទ្រអាវុធនិងហិរញ្ញវត្ថុពីចិន រហូតដល់បានជ័យជំនះថ្ងៃទី១៧មេសា១៩៧៥ ។ ស្តេចសីហនុ, ប្រធានរណសិរ្សរួបរួមបង្រួមជាតិកម្ពុជា បានត្រូវគេលើកឡើងឲ្យធ្វើជា <ប្រធានាធិបតីទី១នៃកម្ពុជាប្រជាធិបតេយ្យ> រហូតទល់ថ្ងៃទី២មេសា១៩៧៦ ។

នេះហើយជាភស្តុតាងបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ អំពីការពាក់ព័ន្ធរបស់ស្តេចសីហនុជាមួយក្រុមខ្មែរក្រហម ដែលជាក្រុមអនុវត្តន៍អំពើសម្លាប់រង្គាលនៅក្នុងប្រទេសកម្ពុជា ។

បើតុលាការអូសកតែពួកមេខ្មែរក្រហមដូចខៀវ-សំផន, អៀង-សារី, នួន-ជា, តាម៉ុក, នាយឌុច ។ល។ និង ។ល។ យកទៅកាត់ទោស រួចហើយគេរំលងមិនបានអូសស្តេចសីហនុទេ នោះការកាត់ទោសប្រាកដជាពុំមានយុត្តិធម៌សោះឡើយ ។

គឺដូចលោកហ្សាក់-វែរហែស្រ (មេធាវីរបស់ខៀវ-សំផន) សរសេរនៅក្នុងអត្ថបទមួយចុះនៅទំព័រខាងមុខនៃសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់» របស់ខៀវ-សំផនដូច្នោះថា ៖ «ជំហររបស់ខៀវ-សំផន វាគ្មានខុសអ្វីប៉ុន្មានពីជំហររបស់សម្តេចនរោត្តម-សីហនុទេ... អ្វីដែលខុសគ្នានោះ គឺនៅត្រង់ឋានៈសង្គមតែប៉ុណ្ណោះ» ។

ហេតុដូច្នេះ, គេពុំអាចកាត់ទោស<ប្រធានាធិបតីកម្ពុជាប្រជាជាធិតេយ្យទី២> ដោយរំលងនិងដោយធ្វើជាមិនឃើញ <ប្រធានាធិបតីកម្ពុជាប្រជាធិបតេយ្យទី១> បានឡើយ ។

យើងធ្លាប់បានឮស្តេចសីហនុមានបន្ទូលថា ព្រះអង្គនឹងស្ម័គ្រយាងចូលទៅឲ្យតុលាការកាត់ទោសព្រះអង្គមុនគេ ។ តែដល់ក្រោយយូរបន្តិចមក ស្តេចសីហនុក៏កែប្រែថា ព្រះអង្គមិនអាចយាងចូលឲ្យតុលាការបង្កើតនៅក្នុងស្រុកខ្មែរកាត់ទោសព្រះអង្គបានឡើយ ពីព្រោះមកពីគ្មានកិត្តិអន្តរជាតិ ។ ស្តេចសីហនុបានស្នើបង្កើតតុលាការនៅបរទេសវិញ ។ ក៏ប៉ុន្តែទោះបីយ៉ាងណា រឿងបង្កើតតុលាការនេះ តាមពិតទៅ វាពុំមែនជាការជ្រើសរើសរបស់ជនជាអ្នកមានពិរុទ្ធនោះឯណា តែវាផ្តោតទៅលើ «យុត្តិធម៌» ដែលជាមូលដ្ឋានសំខាន់ ។ យើងសង្ឃឹមថា អង្គការសហប្រជាជាតិនឹងក្លាយទៅជា«អ្នកគ្រប់គ្រង»លើប្រព័ន្ធនៃតុលាការនេះ ។ បើពុំដូច្នោះទេ វាជាការបង្ខាតបង់ប្រាក់កាស និងពេលវេលាឥតប្រយោជន៍។៚

សម្លេងខ្មែរនៅបរទេស

# នរោត្តម_សីហនុ ប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ

ដោយ លី-ឌៀប ★ ថ្ងៃទី១៤ មេសា ២០០៤

ខាងក្រោមនេះជាឯកសារដកស្រង់ចេញពីសំណុំឯកសារចងក្រងដោយលោក Douglas Pike (ថ្ងៃទី៣០មេសាឆ្នាំ១៩៧៥) ក្រោមចំណងជើងថា ៖ «សមាជពិសេសបញ្ជាក់អំពីមុខតំណែងសីហនុ និងជំហរនយោបាយ» ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ ៖

«សមាជជាតិពិសេស»ខ្មែរមួយ ដែលធ្វើឡើងមួយអាទិត្យបន្ទាប់ពីការធ្លាក់នៃទីក្រុងភ្នំពេញ បានបញ្ជាក់ថា ស្តេចសីហនុគឺជាប្រមុខរដ្ឋ និងជាប្រធាននៃរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា (NUFC) ហើយប៉ែន-នុត គឺជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (RGNU) ព្រមទាំងជានាយកនៃគណៈកម្មាធិការមជ្ឈឹមនៃរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា ។ យោងតាមទីភ្នាក់ងារពត៌មានចិនថ្មី (NCNA), អ្នកដឹកនាំទាំងពីរកំពុងស្ថិតនៅក្នុងទីក្រុងប៉េកាំងនៅឡើយ, សីហនុស្ថិតនៅជាមួយម្តាយ ដែលសុគតនៅថ្ងៃទី២៧មេសាក្រោមមានជម្ងឺព្យាធិយ៉ាងយូរ ។ គេពុំបានបញ្ជាក់អំពីទីកន្លែងពិតប្រាកដ នៃការធ្វើសមាជថ្ងៃទី២៥-២៧មេសាទេ ។ ឧបនាយករដ្ឋមន្ត្រីខៀវ-សំផន បានធ្វើជាអធិបតីភាព ហើយនិងក៏ជាអ្នកអាននូវសេចក្តីថ្លែងការណ៍ពត៌មាននៃសមាជថ្ងៃទី២៨មេសានោះផងដែរ ដែលគេបានយកទៅចាក់ផ្សាយតាមវិទ្យុភ្នំពេញ ។

សេចក្តីថ្លែងការណ៍សមាជ បាននិយាយជ្រៅជាងពីសេចក្តីប្រកាសនៃសមាជរណសិរ្សកាលពីខែកុម្ភៈទើបកន្លងមកនិងកាលពីឆ្នាំ១៩៧៣ទៅទៀត ដោយផ្តោតទៅលើការកោតសរសើរជាឯកជន ចំពោះសីហនុនិងប៉ែន-នុត ។ សេចក្តីថ្លែងការណ៍នេះនិយាយថា សីហនុគឺជា«បុគ្គលស្នេហាជាតិលំដាប់ថ្នាក់កំពូល» រីឯប៉ែន-នុតគឺជា«បុគ្គលស្នេហាជាតិលំដាប់ថ្នាក់ជាន់ខ្ពស់», រួចហើយគេនិយាយថា អ្នកទាំងពីរបានធ្វើនូវ«សកម្មភាពយ៉ាងសស្រាក់សស្រាំ» ផ្តល់ដល់ការតស៊ូនៃរណសិរ្សកន្លងមក ។ ក៏ប៉ុន្តែជាការផ្ទុយទៅវិញ, គេប្រទះឃើញមានឃ្លាតែមួយគត់និយាយអំពីសីហនុនិងប៉ែន-នុត នៅក្នុងសេចក្តីថ្លែងការណ៍សមាជរណសិរ្សកាលពីថ្ងៃទី២៦កុម្ភៈ១៩៧៥ គឺអំពីមុខតំណែងប៉ុណ្ណោះ ដោយពុំបាននិយាយដល់ការខិតខំជួយឧបត្ថម្ភរបស់អ្នកទាំងពីរទេ ។ សេចក្តីថ្លែងការណ៍ចុះថ្ងៃទី២១កក្កដា១៩៧៣ នៃសមាជលើកទីមួយ បានគូសបញ្ជាក់អំពីតួនាទីរៀងៗខ្លួនរបស់សីហនុនិងប៉ែន-នុតជាច្រើនលើកច្រើនសារ តែពុំបានធ្វើការកោតសរសើរអ្វីជាពិសេសវិសាលនោះទេ ។

★ **ការគ្រប់គ្រងប្រជាជន និងនយោបាយអព្យាក្រឹត្យ** ៖

ជាតឹកតាងក្នុងការប្រឹងប្រែង ដើម្បីបង្ហាញឲ្យឃើញនូវអត្ថិភាពនៃការគាំទ្រជាទូទៅរបស់ប្រជាជន, សេចក្តីថ្លែងការណ៍បានសង្កត់ខុសប្លែកពីធម្មតា ទៅលើតួនាទីយ៉ាងសំខាន់ដែលនៅក្នុងពេលឥឡូវនេះកំពុងដើរតួដោយ«ប្រជាជនកម្ពុជា» ហើយនិង«អង្គការមហាជន»របស់ពួកគេជំនួសតួនាទីរបស់រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា (NUFC) និងរបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (RGNU) ។ ដល់ដូច្នេះទៅ, មិនដូចសេចក្តីប្រកាសនៃសមាជលើកមុនទេ, សេចក្តីប្រកាសបច្ចុប្បន្ននេះបានផ្តល់អំណាចឲ្យទៅ«អង្គការមហាជន» ស្ថិតនៅពីលើរណសិរ្សបង្រួបបង្រួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា រួចហើយបានគូសបញ្ជាក់អំពី«ឆន្ទៈប្រជាជន» ថាជាប្រភពនៃភាពស្របច្បាប់សំរាប់នយោបាយថ្មីនេះ ។

សេចក្តីថ្លែងការណ៍ក៏បានបង្ហាញឲ្យឃើញផងដែរថា របបថ្មីចង់បំផុសឲ្យមានសមភាពសេដ្ឋកិច្ច ដោយបំបាត់«មិនឲ្យមានអ្នកមាន ឬអ្នកក្រ, មិនឲ្យមានវណ្ណៈជិះជាន់គេ និងវណ្ណៈត្រូវគេជិះជាន់»ជាដើម... ។ ការសន្យាអនុវត្តន៍ បានត្រូវទទួលការគាំទ្រយ៉ាងទូលំទូលាយពីសមាជ ។

សេចក្តីថ្លែងការណ៍សមាជបានគូសបញ្ជាក់សារជាថ្មី អំពីការប្រកាន់របស់ខ្មែរចំពោះជំហរនយោបាយអព្យាក្រឹត្យ ព្រមទាំងបានបញ្ចេញសម្លេងបញ្ជាក់ប្រាប់ឲ្យដឹង អំពីការហាមឃាត់«ប្រទេសណាទាំងអស់ តាំងមូលដ្ឋានទ័ពនៅក្នុងប្រទេសកម្ពុជា» ដែលជាការខុសប្លែកគ្នាបន្តិចពីសមាជកាលពីខែកុម្ភៈ១៩៧៥ ហាមឃាត់ប្រឆាំងការតាំងមូលដ្ឋានបរទេសដោយ«អំពើឈ្លានពាន» ។ សេចក្តីថ្លែងការណ៍បច្ចុប្បន្នសំដែងឲ្យឃើញនូវការជំទាស់គ្រប់បែបផែននៃអន្តរាគមន៍បរទេស ហើយនិងបាននិយាយយ៉ាងល្អិតល្អន់អំពីការសុខចិត្តទទួលយកជំនួយឥតលក្ខខ័ណ្ឌ ដោយពោលបញ្ជាក់ថា បើជា«អំពើវិទ្ធង្សនានិងអំពើឈ្លានពាន» នៅក្រោមរនាំងសម្ងាត់«ដែលគេហៅថាជំនួយមនុស្សធម៌»នោះ គឺមិនអាចទទួលយកបានសោះឡើយ ។ មិនដូចគ្នានឹងសេចក្តីថ្លែងប្រកាសនៃសមាជលើកមុនទេ សេចក្តីថ្លែងការណ៍លើកនេះ ពុំបានរិះគន់រដ្ឋាភិបាលសហរដ្ឋអាមេរិកដោយចំៗឈ្មោះឡើយ ទោះបីមានការវាយប្រហារទៅលើ «គំនិតមូលធននិយមរបស់សហរដ្ឋអាមេរិក» យ៉ាងណាក៏ដោយ ។

★ **ការប្រព្រិត្តរបស់ក្រុងប៉េកាំង** ៖

ក្រោយពេលការអបអរសាទរយ៉ាងសប្បាយរីករាយរបស់ចិន ចំពោះរណសិរ្សវាយយកបានទីក្រុងភ្នំពេញមក, កាសែតនៅប៉េកាំងបានផ្តោតចំណាប់អារម្មណ៍លើការចូលទីវង្គតនៃព្រះមាតារបស់សីហនុ គឺព្រះមហាក្សត្រីយានីស៊ីសុវត្ថិ-កុសុមៈ ហើយនិងការវិលត្រឡប់មកនៃគណៈប្រតិភូពួកអ្នកកាសែតចិន ពីដំណើរទស្សនកិច្ចនៅក្នុងតំបន់រំដោះនៅប្រទេសកម្ពុជា ។

លិខិតចូលរួមមរណទុក្ខព្រះមហាក្សត្រីយានី ថ្ងៃទី២៨មេសា ចុះហត្ថលេខាដោយប្រធានបក្សកុម្មុយចិន ជូ-ទី និងដោយនាយករដ្ឋមន្ត្រីជូ-អេនឡាយ, បានសំដែងឲ្យឃើញនូវសេចក្តីសង្ឃឹមថា សីហនុមុខជា «បង្វែរពីទុក្ខព្រួយទៅការរឹងមាំ» ដើម្បីធ្វើការកសាងស្រុកខ្មែរឡើងវិញ ។ ជាមួយគ្នានេះផងដែរ នាថ្ងៃទី២៨មេសា សីហនុបានទទួលនូវការទៅចូលរួមរំលែកមរណទុក្ខ ពីថ្នាក់ជាន់ខ្ពស់ចិនស្ថិតនៅក្រោមការដឹកនាំរបស់ឧបនាយករដ្ឋមន្ត្រីតេង-សាវពីង និងចិន-ហ៊ីលាង សំដែងនូវការគោពដល់ព្រះរាជដំណាក់ក្រុងប៉េកាំង ។ អ្នកទូរស័ព្ទទៅសំដែងការក្រៀមក្រំមានរួមទាំងតេង-យ៉ីងចាវ, ជាភរិយារបស់ជូ-អេនឡាយ, ដែលធ្លាប់បានចូលទៅសួរសុខទុក្ខព្រះមហាក្សត្រីយានីមុនពេលសុគត, នេះបើយោងតាមទីភ្នាក់ងារពត៌មានចិនថ្មី ។ កម្រងផ្កាបូជាសពបានធ្វើតាងនាមម៉ៅ-សេទុង, ជូ-អេនឡាយ, តេង-សាវពីង, ជៀង-ជីង និងតេង-យ៉ីងចាវ ។ ទង់ជាតិបានត្រូវគេទម្លាក់ពាក់កណ្តាល នៅទីលាន ជានអាមិន និងនៅតាមការិយាល័យរដ្ឋផ្សេងៗ ។

ទីក្រុងប៉េកាំងមានការចាប់អារម្មណ៍យ៉ាងខ្លាំង ទៅលើការវិលត្រឡប់វិញនៃគណៈប្រតិភូពួកអ្នកកាសែតចិនចំនួន៩នាក់ ពីដំណើរទស្សនកិច្ចចំនួន១៥ថ្ងៃនៅក្នុង«តំបន់រំដោះប្រទេសកម្ពុជា» នារយៈពេលចុងពាក់

ខែមិនា ។ គណៈប្រតិភូបានទទួលនូវការស្វាគមន៍កាលពីថ្ងៃទី២៣មេសា ពីសមាជិកការិយាល័យនយោបាយ យ៉ាវ-វិនយុង និងជី-តេងគួយ ។ យោងតាមទីភ្នាក់ងារពត៌មានចិនថ្ងៃទី២២មេសា, គណៈប្រតិភូនូវការជួបសន្ទនាគ្នាយ៉ាង«កក់ក្ដៅនិងប្រកបដោយមិត្តភាព» ជាមួយខៀវ-សំផន ហើយនិងបានទទួលនូវការជប់លៀងកិត្តិយស ក្រោមអធិបតីភាពនៃរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ហ៊ូ-នឹម ព្រមទាំងរដ្ឋមន្ត្រីក្រសួងឃោសនាការ ហ៊ូ-យន់ នារយៈពេលធ្វើដំណើរនៅក្នុងតំបន់ស្ថិតនៅក្រោមការត្រួតត្រារបស់រណសិរ្ស ។

សេចក្ដីរាយការណ៍ពីរនៃទីភ្នាក់ងារពត៌មានចិនថ្មី ធ្វើដោយគណៈប្រតិភូកាលពីថ្ងៃទី២៤និង២៨មេសា បានសំដែងឲ្យឃើញនូវអត្ថាធិប្បាយរបស់ក្រុងប៉េកាំង សង្កត់យ៉ាងធ្ងន់ទៅលើបញ្ហាខ្មែរ ចាប់តាំងពីពេលរលំដួលនៃទីក្រុងភ្នំពេញមក... តួយ៉ាងដូចជារណសិរ្សប្រើប្រាស់យុទ្ធសាស្រ្តសង្រ្គាមប្រជាជន ហើយនិង«ល្បិច»ឆ្ពោះទៅរកជ័យជំនះ ព្រមទាំង«ឯកភាពយ៉ាងជិតស្និទ្ធដើម្បីបង្កើនកម្លាំងនិងអភិវឌ្ឍន៍ការតស៊ូសាមគ្គីភាព» រវាងប្រជាជនចិននិងកម្ពុជាជាដើម ។ សេចក្ដីរាយការណ៍ទី១រៀបរាប់អំពីវីរៈបុរសជួរមុខនៃកងទ័ពរណសិរ្ស ដែលបានព័ទ្ធទីក្រុងភ្នំពេញនាពេល«យប់»មុនពេលទីក្រុងធ្លាក់ ហើយក៏បាននិយាយរំលឹកផងដែរអំពីការស្វាគមន៍យ៉ាង«កក់ក្ដៅនិងយ៉ាងស្មោះស្ម័គ្រ» ពីសុន-សេន «មេបញ្ជាការ»រណសិរ្សនៅភ្នំពេញ ។ សេចក្ដីរាយការណ៍ទី២ រៀបរាប់អំពីឧប្បត្តិហេតុបញ្ចេញឲ្យឃើញនូវឆន្ទៈដ៏ល្អរបស់កម្ពុជាចំពោះគណៈប្រតិភូ ហើយនិងការគោរពសក្ការៈចំពោះប្រធានម៉ៅ ព្រមទាំងពិធីស្វាគមន៍ទទួលគណៈប្រតិភូ ធ្វើឡើងដោយដោយខៀវ-សំផន និងពិធីជប់លៀងជាកិត្តិយសរៀបចំដោយហ៊ូ-យន់និងហ៊ូ-នឹម ។

ការធ្វើអត្ថាធិប្បាយរបស់រណសិរ្សអំពីទស្សនកិច្ចចិន បានត្រូវគេចុះផ្សាយនៅក្នុងសេចក្ដីថ្លែងការណ៍ទីភ្នាក់ពត៌មានខ្មែរ (AKI) ថ្ងៃទី២២ មេ-សា និងនៅក្នុងសេចក្ដីរាយការណ៍នៃទីភ្នាក់ងារពត៌មានខ្មែរថ្ងៃទី២៦មេ-សា អំពីពិធីជប់លៀងភោជនាហារថ្ងៃត្រង់ថ្ងៃទី២៨មេសា សំរាប់ពួកអ្នកកាសែតចិន ក្រោមការចាត់ចែងនៃសមាជិកការិយាល័យរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា ។

★★★ វត្ថុបំណងដែលយើងលើកយកអត្ថបទនេះមកបង្ហាញជូនជនរួមជាតិ គឺគ្មានអ្វីក្រៅអំពីចង់បញ្ជាក់ថា ៖ ស្ដេចសីហនុ គឺពិតជាបានទទួលនូវមុខតំណែងជា «ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ» យ៉ាងប្រាកដមែន រួចហើយរណសិរ្សបង្រួបបង្រួមជាតិកម្ពុជា ដែលស្ដេចសីហនុបានហៅថាជា«កងទ័ពរំដោះ»នោះ គឺគ្មានអ្វីក្រៅអំពីជា «កងទ័ពខ្មែរក្រហម» ដែលជាក្រុម«ឃាតករ» យ៉ាងសាហាវឃោរឃៅនៃ«ទីលានពិឃាដខ្មែរ» នោះទេ ។

យើងពុំអាចទទួលយកបានសោះឡើយ នូវការកាត់ទោសពួកមេខ្មែរថ្នាក់បន្ទាប់ តួយ៉ាងដូចជា «តាម៉ុកនិងនាយឌុច» ជាដើម ។ល។ នៅទន្ទឹមពេលគេត្រូវធ្វើជាខ្វាក់ភ្នែក និងមើលមិនឃើញ«មេឃាតករ»ដ៏ធំអស្ចារ្យម្នាក់ទៀតឈ្មោះ «នរោត្តម-សីហនុ» ។ អំពើយុត្តិធម៌ពិតជាមិន«ត្រឹមត្រូវ»ទាល់តែសោះ បើប្រសិនណាឈ្មោះនរោត្តម-សីហនុ ត្រូវគេទុកបណ្ដោយឲ្យរស់នៅយ៉ាងរំភើយបែបនេះ ។

សម្លេងខ្មែរនៅបរទេស

# កម្ពុជាបញ្ជាក់អំពីទស្សនកិច្ចរបស់ឡែ្វ-យន់ ដើម្បីពិភាក្សាអំពីបញ្ហានយោបាយការបរទេស

ដោយ លី-ឌៀប ★ ថ្ងៃទី១៦ មេសា ២០០៤

ខាងក្រោមនេះជាឯកសារដកស្រង់ចេញពីសំណុំឯកសារចងក្រងដោយលោក Douglas Pike (ថ្ងៃទី៦សីហាឆ្នាំ១៩៧៥) ក្រោមចំណងជើងថា ៖ «កម្ពុជាបញ្ជាក់អំពីទស្សនកិច្ចរបស់ឡែ្វ-យន់ ដើម្បីពិភាក្សាអំពីបញ្ហានយោបាយការបរទេស» ។ ចំណុចដែលគួរឲ្យចាប់អារម្មណ៍ជាទីបំផុតនោះ គឺពួកខ្មែរក្រហមបានហៅមេយួននេះ ចូលមកនិយាយគ្នានៅក្នុងទីក្រុងភ្នំពេញ មួយខែមុនពេល«ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ» គឺស្តេចនរោត្តម-សីហនុយាងចូលស្រុក ។

ថ្ងៃទី១៩ ឧសភា, ស្តេចសីហនុអន់ចិត្តនឹងពួកខ្មែរក្រហម មិនគិតគូរមុខតំណែងអ្វីដល់ព្រះអង្គ ក៏ងរលលះលលាំងទៅសម្ងំក្រុងព្យុងយ៉ាងប្រទេសកូរ៉េខាងជើង ។

ថ្ងៃទី១៨ កក្កដា, សារិន-ឆាកនិងជួន-ប្រាសិទ្ធបាននាំគ្នាទៅព្យុងយ៉ាង ដើម្បីអង្វរករសុំឲ្យស្តេចសីហនុយាងចូលស្រុក ។ តែស្តេចសីហនុប្រកែកមិនយល់ព្រម ។

ថ្ងៃទី៣ សីហា, ឡែ្វ-យន់ចូលទៅដល់ភ្នំពេញ ដើម្បីនិយាយគ្នាអំពីបញ្ហាព្រំដែន បន្ទាប់ពីមានការប៉ះទង្គិចអាវុធគ្នានៅកោះកុង និងបន្ទាប់ពីយួនកាន់កាប់កោះប៉ូឡូវ៉ៃរួចមក ។

ថ្ងៃទី១៨ សីហា, ខៀវ-សំផនរត់ទៅពឹងប៉ែន-នុត ដើម្បីឲ្យទៅជួយអង្វរស្តេចសីហនុ ។ ប៉ែន-នុតធ្លាប់ដឹងចិត្តស្តេចសីហនុ ក៏ទូលស្តេចសីហនុថាខាងកម្ពុជាប្រជាធិបតេយ្យសន្យាថ្វាយមុខតំណែង«ប្រមុខរដ្ឋ» អស់មួយជីវិតថ្វាយព្រះអង្គ ។ ស្តេចសីហនុក៏យល់ព្រមភ្លាម ។

ថ្ងៃទី២ កញ្ញា, ស្តេចសីហនុមិនចូលស្រុកតែម្តងទេ ព្រះអង្គយាងចាក់ផែវចុះនៅហាណូយសិន ដើម្បីសុំនូវការធានាពីយួន ។

ថ្ងៃទី៩ កញ្ញា, បន្ទាប់ពីគង់នៅហាណូយអស់១អាទិត្យ ទើបព្រះអង្គស្តេចយាងចូលក្រុងភ្នំពេញ ។

★ នេះហើយអាកប្បកិរិយាដ៏ថោកទាបនៃស្តេចខ្មែរ ។ សូមអញ្ជើញអានឯកសាររបស់លោក Douglas Pike ដូចតទៅ ៖

«សេចក្តីថ្លែងការណ៍ព័ត៌មាន»កំបុតថ្ងៃមួយ បានត្រូវគេចាក់ផ្សាយតាមវិទ្យុភ្នំពេញ កាលពីថ្ងៃទី៣សីហា ប្រកាសឲ្យដឹងអំពីទស្សនកិច្ចនាពេលថ្មីៗនេះមកកាន់ប្រទេសកម្ពុជា នៃគណៈប្រតិភូពលករវៀតណាម ស្ថិតនៅក្រោមការដឹកនាំរបស់លេខាធិការទី១ ឡែ្វ-យន់ ដែលគាត់និយាយថា ទំនាក់ទំនងរវាងប្រទេសទាំងពីរ កំពុងមានសភាពតឹងតែងនៅឡើយ ។ ក្នុងខណៈពេលយួនខាងជើង ជាប្រទេសទី១ដែលបានបញ្ជូនគណៈប្រតិភូរបស់ខ្លួនមកកាន់កម្ពុជា ចាប់តាំងពីជ័យជំនះខែមេសាកន្លងមកនេះ, សេចក្តីថ្លែងការណ៍អង្គប្រជុំហាក់ដូចជាមានការប្រុងប្រយ័ត្ន ផ្ទុយពីសេចក្តីថ្លែងការណ៍កាលពីពេលប្រជុំខ្មែរ-យួនលើកមុនៗ ។ គ្រាន់តែមួយថ្ងៃប៉ុណ្ណោះ បន្ទាប់សេចក្តីប្រកាសឲ្យដឹងពីទស្សនកិច្ចចុងក្រោយនេះ, វិទ្យុភ្នំពេញបានរាយការណ៍អំពីការពង្រឹងទ័ពទឹង នៅលើកោះនានាក្នុងឈូងសមុទ្រសៀម ដែលធ្លាប់កាន់កាប់ដោយរដ្ឋាភិបាលយួនខាងត្បូងនៅមុនពេលពួកកុម្មុយនិស្តវាយយកបានវៀតណាម ។ វិទ្យុភ្នំពេញ នាពេលថ្មីៗ ក៏បានធ្វើឲ្យផ្ទុះលេចឮផងដែរ អំពីបញ្ហានយោបាយការបរទេសផ្សេងទៀតជាលើកទី១ ទាក់ទងទៅនឹងការផ្តល់ជំនួយរបស់ចិននៅក្រោយពេលសង្គ្រាម ហើយនិងបានគូសបញ្ជាក់អំពីចំណាប់អារម្មណ៍របស់ទីក្រុងបាងកក ចង់សំរួលទំនាក់ទំនងការទូតជាមួយកម្ពុជា ។

★ <u>ទស្សនកិច្ចរបស់ឡែ្វ-យន់</u> ៖

តាមមើលទៅ ប្រហែលខុសប្លែកពីការរុញរាក្នុងចិត្តរបស់ខ្មែរ ចាប់តាំងពីពេលពួកកុម្មុយនិស្តកាន់ក្តាប់អំណាចមក ក្នុងការផ្សព្វផ្សាយព័ត៌មានឲ្យគេបានដឹងអំពីលំដាប់ថ្នាក់ដឹកនាំរបស់ខ្លួន នៅក្នុងសេចក្តីថ្លែងការណ៍ទស្សនកិច្ចរបស់ឡែ្វ-យន់ ដោយមិននិយាយប្រាប់ពីពេលវេលា ឬទីកន្លែងដែលគេជួបនិយាយគ្នានៅក្នុងស្រុកខ្មែរ ឬក៏អំពីអ្វីដែលពួកមេដឹកនាំខាងខ្មែរនិយាយជាមួយយួនឡើយ ។ ពួកសមាជិកគណៈប្រតិភូខាងយួនក្រៅពីឡែ្វ-យន់ចេញ ក៏ដូចគ្នាដែរ គឺគេមិនបានបញ្ចេញឲ្យស្គាល់ទេ ។ សេចក្តីរាយការណ៍នៅហាណូយស្តីអំពីទស្សនកិច្ច ផ្សព្វផ្សាយដោយទីភ្នាក់ងារព័ត៌មានវៀតណាមកាលពីថ្ងៃទី៣ មានលក្ខណៈដូចគ្នានឹងវិទ្យុភ្នំពេញដែរ ទោះបីគេមិនបានដាក់ថាជាសេចក្តីថ្លែងការណ៍ក៏ដោយ ។ បទវិចារណកថាមួយអំពីទស្សនកិច្ចនៅក្នុងកាសែតញ៉ាងយ៉ឺងរបស់យួនខាងជើង នៅក្នុងថ្ងៃដដែល ក៏ពុំមាននិយាយអ្វីជាពិស្តារបន្ថែមឡើយ ។

ផ្ទុយទៅវិញ, កាលពីមុនពេលចប់សង្គ្រាមឥណ្ឌូចិន, កាសែតខ្មែរនិងយួន បានផ្តល់នូវព័ត៌មានយ៉ាងវែងអន្លាយ និយាយអំពីទស្សនកិច្ចនៃគណៈប្រតិភូប្រទេសទាំងពីរ ចាប់ពីសុន្ទរកថានៅក្នុងពេលជប់លៀងរហូតដល់ទៅការធ្វើសេចក្តីថ្លែងការណ៍រួមជាដើម ។ តាមពិតទៅ, ឡែ្វ-យន់បានដឹកនាំគណៈប្រតិភូយួនតាំងតែដើមរហូតមក ។ ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស, លេខាធិការទី១រូបនេះ បានដឹកនាំគណៈប្រតិភូទៅកាន់ពួកប្រទេសសម្ព័ន្ធមិត្តកុម្មុយនិស្តហាណូយសំខាន់ៗ ដូចជាទៅប៉េកាំងកាលពីខែមិថុនា១៩៧៣ និងទៅកាន់ទីក្រុងមូស្គូនាខែបន្ទាប់ រួចហើយឆ្ពោះទៅប្រទេសលាវកាលពីខែវិច្ឆិកា១៩៧៣ ដែលជាដំណើរទស្សនកិច្ចទៅកាន់បរទេសចុងក្រោយបង្អស់របស់គាត់ ។

ដូចគ្នាដែលទៅនឹងលទ្ធផលនៃការជួបគ្នាខ្មែរ-យួននាពេលមុនៗដែរ សេចក្តីថ្លែងការណ៍ទស្សនកិច្ចនិយាយថា គ្រប់បញ្ហាទាំងអស់ក្នុងរយៈពេលធ្វើទស្សនកិច្ចបានទទួលនូវការព្រមព្រៀងគ្នាជាឯកច្ឆន្ទ ។ អត្ថាធិប្បាយនៃកាសែតញ៉ាងយ៉ឺងបានគូសបញ្ជាក់ថា លទ្ធផលយ៉ាង«ល្អប្រសើរ»បានផ្តល់ឡើងនៅក្នុងដំណើរទស្សនកិច្ច ។ តែទោះបីដូច្នេះក៏ដោយ កាសែតនិយាយថា បរិយាកាសស្ថិតនៅជុំវិញដំណើរទស្សនកិច្ចប្រកបទៅដោយការយោគយល់គ្នាទៅវិញទៅមក ល្អប្រសើរជាងទស្សនកិច្ចកាលពីលើកមុនៗ ។ ដូចគ្នាទៅនឹងសេចក្តីថ្លែងការណ៍រួម រវាងប្រធានាធិបតីនៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន (រដ្ឋាភិបាលយៀកកុង) ផាត់ធ្វើឡើងជាមួយខៀវ-សំផន កាលពីខែធ្នូឆ្នាំ១៩៧៤ដែរ និយាយថាការជួបគ្នាបានប្រព្រឹត្តទៅក្នុងបរិយាកាស«រាក់ទាក់, មិត្តភាពកក់ក្តៅ និងសាមគ្គីប្រយុទ្ធតស៊ូ» ។ ឡែ្វ-យន់ ត្រូវគេរាយការណ៍ថា «បានធ្វើការពិភាក្សាយ៉ាងរាក់ទាក់ ក្រោមបរិយាកាសជាបងប្អូន» ក្នុងពេលទស្សនកិច្ចថ្មីៗរបស់គាត់ ។ សេចក្តីថ្លែងការណ៍រួមក្នុងពេលទស្សនកិច្ចរបស់ខៀវ-សំផន កាលពីខែមេសាឆ្នាំ១៩៧៤នៅហាណូយនិយាយថា «ទស្សនកិច្ចពោរពេញទៅដោយជោគជ័យ និងបានផ្តល់នូវកម្លាំងយ៉ាងខ្លាំង ព្រមទាំងការរួមសំបាច់តស៊ូជាធ្លុងមួយ ហើយនិងមិត្តភាពដ៏ធំធេង» រវាងប្រទេសទាំង២

ដែលអាចបកស្រាយ «នៅក្នុងមនោសញ្ចេតនាដ៏ភ្លឺស្វាង នៅក្នុងសាមគ្គីតស៊ូប្រយុទ្ធ និងនៅក្នុងមិត្តភាពដែលពុំអាចបំបែកបានឡើយ» ដែលចង់ភ្ជាប់គ្នារវាងប្រជាជនទាំងពីរ ។ តែជាការផ្ទុយទៅវិញ ទស្សនកិច្ចរបស់ឡៃ-យន់លើកនេះ ស្ទើរតែពុំមាននូវពាក្យ «ពង្រឹងចំណងតស៊ូសាមគ្គីប្រយុទ្ធ និងមិត្តភាពតទៅមុខទៀត» រវាងយៀកណាមនិងកម្ពុជាទេ ។

★ **ព្រំដែនកោះ** ៖

កាលពីថ្ងៃទី៨សីហា វិទ្យុភ្នំពេញបានរាយការណ៍ថា កងទ័ពខ្មែរបានកាន់កាប់នៅលើកោះទន្សាយនិងកោះពោ នៅក្នុងឈូងសមុទ្រសៀមជិតស្រុកយួនខាងត្បូង «នៅក្នុងពេលចក្រពត្តិអាមេរិកាំង និងពួកធីវជាអាយ៉ងបាវបំរើ បានត្រូវបោសសំអាតមួយរំពេជចេញពីទឹកដីរបស់យើង » ។ នេះជាសេចក្តីរាយការណ៍លើកដំបូងបង្អស់របស់ភ្នំពេញ ស្តីអំពីការកាន់កាប់កោះ ដែលពួកយួនខាងត្បូងធ្លាប់អះអាងថាជារបស់ភិនខ្លួន ចាប់តាំងពីពេលកើតមានព្រឹត្តិការណ៍នាវា Mayaguez កាលពីចុងខែឧសភាមក ។ កាលនៅពេលនោះ វិទ្យុភ្នំពេញបាននិយាយជាច្រើនលើក អំពីវិធានការកងទ័ពដែលត្រូវបានអនុវត្តនៅលើកោះ ដែលធ្លាប់បានអះអាងថាជារបស់យួនខាងត្បូង ដូចនៅក្នុងការផ្សាយកាលពីថ្ងៃទី១៨ឧសភានិយាយថា កម្លាំងកងទ័ពជើងទឹកខ្មែរនៅកោះវៃ បានត្រូវទទួលនូវការកោតសរសើរអំពីវីរៈភាពរបស់ពួកគេ ប្រឆាំងនឹងអាមេរិកាំងជាដើម ។ វិទ្យុភ្នំពេញថ្ងៃទី២៥កក្កដានិយាយថា ប្រជាជននៅលើកោះរ៉ុងសន្លឹម «ប្រដាប់ដោយអាវុធ» បាននាំគ្នាងើបឡើងធ្វើការតស៊ូ ការពារដែនកោះរបស់ខ្លួន ។

★ **ជំនួយរបស់សាធារណរដ្ឋចិនប្រជាមានិត** ៖

វិទ្យុភ្នំពេញបានធ្វើឲ្យដឹង អំពីការបន្តជំនួយចិន នៅក្នុងសេចក្តីរាយការណ៍ប្រចាំថ្ងៃទី៣សីហារបស់ខ្លួន និយាយអំពីសំបុត្រថ្លែងនូវអំណរគុណាមួយច្បាប់ចុះថ្ងៃទី១សីហា ធ្វើឡើងដោយខៀវ-សំផន ផ្ញើទៅជូនរដ្ឋមន្ត្រីក្រសួងការពារជាតិចិន យេ៉-ជាងយុីង ក្នុងឱកាសថ្ងៃបុណ្យកងទ័ពចិន ។ លិខិតបានថ្លែងអំពី «ចំណងមិត្តភាពនិងយោធា យ៉ាងរឹងមាំ»រវាងកម្ពុជានិងចិន ហើយបានបញ្ជាក់ថា កម្ពុជានៅតែបន្តទទួលពីចិននូវ«ការគាំទ្រនិងការជួយជ្រោមជ្រែង» ក្នុង«ដំណាក់ការថ្មី»នៃបដិវត្តន៍កម្ពុជា ចាប់ពីបានរំដោះមក ។ នេះជាលើកទី១ហើយ ចាប់តាំងពីពេលពួកកុម្មុយនិស្តកាន់កាប់ ដែលវិទ្យុភ្នំពេញចាក់ផ្សាយនូវអត្ថបទរបស់មេដឹកនាំខ្មែរ ផ្ញើទៅជូនបរទេស ហើយនិងក៏ជាលើកទីមួយផងដែរ ដែលវិទ្យុចាក់ផ្សាយនូវសេចក្តីថ្លែងការណ៍ចុះហត្ថលេខាដោយខៀវ-សំផន ចាប់តាំងពីចាក់ផ្សាយនូវសេចក្តីថ្លែងការណ៍សមាជជាតិពិសេសកាលពីថ្ងៃទី២៨មេសាមក ។

★ **ប្រទេសថៃ** ៖

នៅក្នុងពត៌មានប្រចាំសប្តាហ៍កាលពីថ្ងៃទី២៧កក្កដា, វិទ្យុភ្នំពេញបានស្វាគមន៍សេចក្តីថ្លែងការណ៍នាពេលថ្មីៗរបស់នាយករដ្ឋមន្ត្រីថៃ យូគ្រឹតដែលប្រទេសថៃរំពឹងទៅលើទំនាក់ទំនងជាមួយកម្ពុជា ។ វិទ្យុបានធ្វើអត្ថាធិប្បាយថា «នេះគឺជាក្តីសង្ឃឹមយ៉ាងល្អប្រសើរបំផុត» ដែលបានកើតមានឡើងសំរាប់ទំនាក់ទំនងដ៏ល្អរវាងប្រទេសទាំងពីរ ។ វិទ្យុបានចាត់ទុកប្រទេសថៃ ក្នុងលក្ខណៈដូចគ្នាស្មើប្រទេសយួននិងលាវដែរ គឺទុកដូចជា«បងប្អូនរួមរស់ជាមួយគ្នា» ។ វិទ្យុដដែល កាលពីថ្ងៃទី៣សីហា ជាលើកទី១ បានធ្វើសេចក្តីរាយការណ៍គាំទ្រនយោបាយនៃពួកប្រទេសមិនមែនកុម្មុយនិស្តជិតខាងដទៃផ្សេងទៀត ដោយធ្វើការរិះគន់បក្សសម្ព័ន្ធសេអាតូ ចំពោះនាយករដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ី រ៉ាហ្សាក់ ព្រមទាំងរដ្ឋាភិបាលប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ ។៚

(សូមអានភាគបន្ត ៖ ខៀវ-សំផនហែរស្តេចសីហនុចូលភ្នំពេញ)

សម្លេងខ្មែរនៅបរទេស

# សីហនុនិងស៊ីដនី-សាន់បឺគ៍
# Sihanouk vs Sydney H. Schanberg

ដោយ លី-ឡៀប ★ ថ្ងៃទី២៣ មេសា ២០០៤

ខាងក្រោមនេះជាប្រតិកម្មរបស់ស្តេចសីហនុ ឆ្លើយតបទៅលោក Sydney H. Schanberg អ្នកសារពត៌មានប្រចាំនៅកាសែតញូវយ៉កថៃមស៍ ស្តីអំពីខ្សែភាពយន្ត «ទីលានពិឃាត» ដែលយើងសូមធ្វើការបកប្រែក្រៅផ្លូវការដូចខាងក្រោមនេះ ៖

«នរោត្តម-សីហនុ

«ប្រធានាធិបតីកម្ពុជាប្រជាធិបតេយ្យ

«ក្រុងស៊ីដនី, ថ្ងៃទី២ មិនា ១៩៨៥

«លោក Sydney H. Schanberg
c/o THE NEW YORK TIMES
NEW YORK, N.Y. (USA)

«លោក,

«នៅក្នុងភាពយន្ត «ទីលានពិឃាត -ការពិតនៅពីក្រោយភាពយន្តទាក់ទងនឹងរឿងផ្ទាល់ខ្លួនរបស់ Sydney Schanberg និងឌិត-ប្រន» (ដកស្រង់ចេញពីសៀវភៅបោះពុម្ពផ្សាយដោយបណ្ណាគារ (Coronet Book - Hodderand Stoughton, 1984), សៀវភៅដែលមិត្តរបស់ខ្ញុំម្នាក់បានយកមកបង្ហាញឲ្យខ្ញុំអានថ្ងៃនេះនៅក្រុងស៊ីដនី (ប្រទេសអូស្ត្រាលី) គឺបានរៀបរាប់យ៉ាងដូច្នេះថា ៖

១- នៅទំព័រទី១១ ៖ «សីហនុអនុញ្ញាតស្បៀងពួកកុម្មុយនិស្ត ដឹកឆ្លងកាត់កំពង់ផែខ្មែរក្រុងព្រះសីហនុ ទៅកាន់តំបន់ព្រំដែនទិសខាងកើតជាប់ជាមួយស្រុកយួន ។ ការដឹកជញ្ជូន, ដែលមានរហូតទល់ឆ្នាំ១៩៧០, បានធ្វើឲ្យចំណេញប្រាក់យ៉ាងសន្ធឹកសន្ធាប់ចំពោះសម្តេច ហើយនិងមេទាហានជាន់ខ្ពស់របស់គាត់» ។

លើទំព័រទី១៣ ៖ ...«បីឆ្នាំក្រោយមក, គាត់ (សីហនុ) បានចំណេញយ៉ាងសន្ធឹកសន្ធាប់ ពីការអនុញ្ញាតបើកផ្លូវដឹកស្បៀងកុម្មុយនិស្តឆ្លងកាត់តាមស្រុកខ្មែរ» ។

ក្នុងជីវិតនយោបាយរបស់ខ្ញុំ (ឆ្នាំ១៩៥៥-១៩៧០), នៅស្រុកខ្មែរ, ខ្ញុំបានធ្វើដូចគ្នានឹងមនុស្សលោកនានានៅលើគពផែនដីនេះដែរ គឺមានការភ័ន្តច្រឡំ និងធ្វើកំហុស ។ ក៏ប៉ុន្តែ, ខ្ញុំពុំដែលបានក្បត់ ឬក៏លួចប្លន់ស្រុកទេសរបស់ខ្ញុំនិងប្រជារាស្ត្ររបស់ខ្ញុំទេ ។ ហើយនៅក្នុងរឿងដឹក «ស្បៀង»ពីក្រុងព្រះសីហនុ ទៅកាន់ព្រំដែនខាងកើតស្រុកខ្មែរនិងវៀតណាមខាងត្បូងនោះទៀតសោត, ខ្ញុំសូមស្បថចំពោះលោកថា ខ្ញុំពុំដែលបានលុយកាក់ ឬបានរបស់របរអ្វីទាំងអស់ពីរឿងនេះទេ ។

ចំពោះអ្វីដែលបានសរសេររៀបរាប់ក្នុងសៀវភៅខាងលើ, កិត្តិយសរបស់ខ្ញុំបានត្រូវរជាន់ឈ្លី ។ ខ្ញុំមានការអាក់អន់ស្រពាន់ចិត្តយ៉ាងខ្លាំងអំពីរឿងនេះ ។

២- នៅទំព័រទី១២, ក្នុងសៀវភៅដដែល, សរសេរថា ៖ «ក្រោយពេលបោះឆ្នោតមានពួកខាងស្តាំច្រើននៅក្នុងរដ្ឋាភិបាល, សីហនុបានអនុញ្ញាតឲ្យនាយករដ្ឋមន្ត្រីថ្មីរបស់គាត់, ឧត្តមសេនិយលន់-នល់, ទៅកំទេចការបះបោរនៃពួកអ្នកស្រុកខាងឆ្វេង ស្ថិតនៅខេត្តខាងលិចបាត់ដំបង (ខ្ញុំសូមគូសបន្ទាត់ពីក្រោមដើម្បីបញ្ជាក់, ន.ស.), និងលួងលោមពួកខាងឆ្វេងនៅភ្នំពេញ ឲ្យចាកចេញពីទីក្រុងទៅចូលរួមពួកបះបោរកុម្មុយនិស្ត», (ខ្ញុំសូមគូសបន្ទាត់ពីក្រោមដើម្បីបញ្ជាក់, ន.ស.) ។

អនុញ្ញាតឲ្យខ្ញុំធ្វើការចង្អុលបង្ហាញដូច្នេះថា ៖ ពួកអ្នកស្រុកតែងតែជាអ្នកស្មោះស្រង់និងជាអ្នកគាំទ្រដ៏ភក្តីរបស់ខ្ញុំជានិច្ច ។ ខ្ញុំមិនដែលធ្វេសប្រហែសមិនយកចិត្តទុកដាក់ចំពោះពួកគេនៅក្នុងបញ្ហានេះទេ, សូមមេត្តាអានសៀវភៅចុះ, កាលពីអឡុងឆ្នាំ៦០, ដែលសរសេរដោយជនជាតិនិងជាមិត្តភក្តិអ្នកកាសែតរបស់លោក គឺលោក Jerrold Schecter ក្រោមចំណងជើង «ព្រះភក្ត្រព្រះពុទ្ធថ្មី», ហើយខ្ញុំក៏ពុំចាំបាច់សំដែងឲ្យឃើញនូវអ្វីទាំងអស់ចំពោះពួកគេដែរ ។ នៅខេត្តបាត់ដំបង, ដែលជាខេត្តខ្មែរដ៏សំបូរសប្បាយជាងគេ និងជាខេត្តដែលពួកអ្នកស្រុកនៅគ្រប់ទិសទីកន្លែងទាំងអស់ មានកិរិតជីវភាពខ្ពង់ខ្ពស់ជាងអ្នកស្រុកនៅតាមខេត្តនានានៃប្រទេសកម្ពុជា -ទីនោះគេពុំដែលមានការបះបោរនៃអ្នកស្រុកទេ, ប៉ុន្តែគឺកើតមាននៅក្នុងតំបន់សំឡូត ដែលជាមូលដ្ឋានយោធាយ៉ាងមាំរបស់ពួកខ្មែរក្រហម ។ អ្វីដែល«ពួកអ្នកប្រវត្តិវិទូ»ចាត់ទុកថា «ការបះបោររបស់ពួកស្រុកនៅសំឡូត, បានត្រូវបង្ក្រាបយ៉ាងយង់ឃ្នងខ្លាំងក្លា ក្រោមបញ្ជារបស់សីហនុនោះ គឺពុំមែនយ៉ាងដូច្នោះទេ, តែតាមពិតទៅ ជាការប្រឈមមុខតទល់គ្នាយ៉ាងសាហាវអស្ចារ្យ រវាងកងទ័ពរបស់ខ្ញុំជាមួយកងទ័ពរបស់លោកប៉ុល-ពតប៉ុណ្ណោះ... ហើយដូចគ្នានេះដែរ, ពេលក្រោយមកទៀត, នៅខែមករានិងកុម្ភៈឆ្នាំ១៩៨៥ មានការប្រយុទ្ធដ៏ធំមួយ រវាងកងកម្លាំងខ្មែរក្រហមប៉ុល-ពត និងពួកខ្មែរកុម្មុយនិស្តប្រហាណូយព្រមទាំងចៅហ្វាយរបស់ពួកគេ, នៅក្នុងតំបន់ភ្នំម៉ាឡៃ ក្នុងខេត្តបាត់ដំបងដដែល ។

៣- នៅទំព័រទី១១ សរសេរថា ៖ «ឆ្នាំ១៩៤១... បារាំងធ្វើមិនដឹងមិនឮចំពោះការត្រូវឡើងស្នងរាជ្យនៃទ្រង់ស៊ិសុវត្ថិ-សិរិមតៈ រួចហើយគេបានលើកទ្រង់នរោត្តម-សីហនុជាជំនួសវិញ» ។

រឿងនេះវាគ្មានទំនាក់ទំនងនឹងការពិតនៃប្រវត្តិសាស្ត្រទេ រួចហើយក៏វាគ្មានពាក់ព័ន្ធនឹងទ្រង់ស៊ីសុវត្ថិ-សិរិមតៈផងដែរ (ដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ព្រះអង្គម្ចាស់, ជាព្រះអង្គម្ចាស់ចុងក្រោយគេបង្អស់នៃសមាជិកព្រះញាតិវង្សខ្មែរ), ក៏ប៉ុន្តែ, សូមអនុញ្ញាតឲ្យយើងគូសបញ្ជាក់ថា, ទ្រង់ស៊ីសុវត្ថិ-សិរិមតៈ, ជាព្រះរាជបុត្ររបស់ព្រះមហាក្សត្រចុងក្រោយ គឺព្រះបាទមុនីវង្ស និងត្រូវជាបងប្រុសរបស់ម្តាយខ្ញុំ ។ នៅពេលសុគតរបស់ព្រះបាទមុនីវង្ស, កាលពីឆ្នាំ១៩៤១, មានបេក្ខជនស្នងរាជ្យតែពីរអង្គគត់ប៉ុណ្ណោះ គឺឪពុករបស់ខ្ញុំ, នរោត្តម-សុរាម្រិត (ដែលស្ថិតនៅក្នុង«ថ្នាក់ជាន់ខ្ពស់» នៃខ្សែរនរោត្តម) ហើយនិងឪពុកមារបស់ខ្ញុំ, ស៊ីសុវត្ថិ-មុនីរ៉េត, ដែលស្ថិតនៅ«ថ្នាក់បន្ទាប់» នៃខ្សែខាងស៊ីសុវត្ថិ ។ ដូច្នេះ ដោយហេតុពុំអាចសំរេចជ្រើសរើសរវាងអ្នកទាំងពីរបាន គឺរវាងឪពុករបស់ខ្ញុំនិងឪពុកមាខាងម្តាយខ្ញុំ, ទើបបារាំងក៏ជ្រើសរើសយកសីហនុទៅ ។ ស៊ីសុវត្ថិ-សិរិមតៈគ្មានងារជាព្រះអង្គម្ចាស់ទេ រួចហើយក៏ពុំអាចមានឱកាសណាឡើងទៅដល់ព្រះរាជបល្ល័ង្កខ្មែរនោះដែរ ។ រឿងនេះជាការពិត ពីព្រោះមកពីហេតុដូច្នេះឯងហើយ បានជាទ្រង់ត្រូវរំពឹងទៅលើមូលហេតុ«សាធារណរដ្ឋ»នោះ ។

«សូមលោកទទួលនូវសេចក្តីរាប់អានយ៉ាងជ្រាលជ្រៅអំពីខ្ញុំ

«ព្រះហត្ថលេខា ៖ នរោត្តម-សីហនុ» ។

★★★ រឿងសំខាន់ដែលយើងលើករាជសារនេះឡើង ពុំមែនការសរសេរបារ៉ាវ៉ារបស់នរោត្តម-សីហនុ ដែលព្រះអង្គតែងតែធ្វើជាវៀ

ងរហូតមកនោះទេ ចំណុចសំខាន់គឺការប្រើ«គោរម្យងារ»របស់ព្រះអង្គជា «ប្រធានាធិបតីកម្ពុជាប្រជាធិបតេយ្យ» ។

សូមធ្វើការសង្កេតពិនិត្យមើលចុះ សូម្បីមកដល់ខែមិនាឆ្នាំ១៩៨៥ (១០ឆ្នាំក្រោមជ័យជំនះរបស់ពួកខ្មែរក្រហម) ទៅហើយក្ដី ក៏នរោត្តម-សីហនុនៅតែពេញចិត្តលើកដំកល់ដំកើងខ្លួនជា «ប្រធានាធិបតី» របស់ពួកខ្មែរក្រហមដដែល ទោះបីអំពើសម្លាប់រង្គាលដ៏មហាព្រៃផ្សៃឃោរឃៅត្រូវពិភពលោកទាំងមូលបានដឹងឮយ៉ាងរន្ធឺសុសសាយក៏ដោយ ។

នេះជាការព្រហើនរបស់នរោត្តម-សីហនុ និងជាការងាកទៅស្ទោះទឹកមាត់ដាក់លើគំនរឆ្អឹងខ្មោចនៃជនរួមជាតិខ្មែរ ដែលជាអ្នករងគ្រោះនៅក្រោមរបបកាប់សម្លាប់<មហាលោតផ្លោះ-មហាអស្ចារ្យ>របស់គាត់ ។

នាពេលថ្មីៗនេះ, យើងបានឮស្ដូរនរោត្តម-សីហនុនិយាយថា ខ្លួននឹងមិនដើរចូលទៅក្នុងតុលាការមួយ ដែលគេរៀបចំឡើងនៅក្នុងទីក្រុងភ្នំពេញដើម្បីកាត់ទោសពួកមេដឹកនាំខ្មែរក្រហមទេ ពីព្រោះដោយសារមកតុលាការនេះមិនត្រឹមត្រូវ ។ ព្រះអង្គចង់បានតុលាការនៅបរទេសវិញ ។

យើងសូមឆ្ងល់ថា ៖ តើនរោត្តម-សីហនុយល់ព្រមសារភាពខ្លួនជា «មេខ្មែរក្រហម» ហើយឬ បានជាចង់ស្ម័គ្រចិត្តដើរចូលឲ្យតុលាការកាត់ទោសយ៉ាងដូច្នេះ ? ។ ធម្មតាមនុស្សបរិសុទ្ធគ្មានទោស គេមិនឆ្គួតលីលាដើរទៅឲ្យនរណាកាត់ទោស<លេងៗ>ឡើយ ។ គឺមានតែមនុស្សមានឈាមប្រឡាក់បាតដៃ ត្រូវខ្មោចបងប្អូនខ្មែររាប់លាននាក់តាមលងទាំងយប់ទាំងថ្ងៃទាំងយប់ប៉ុណ្ណោះ ដែលមានអារម្មណ៍ជាប់ពិរុទ្ធរវើរវាយវង្វេងវង្វាន់បែបនេះ (!!)

នេះហើយដូចពាក្យខ្មែរលោកពោលថា ៖

**“ឈាមស្រែក~ស្បែកហៅ”**

ពីមូលហេតុថា តុលាការនេះគ្មានលក្ខណៈត្រឹមត្រូវ ។ នរោត្តម-សីហនុ